

# បទបង្ហាញ

## ស្តីពី

## “ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និង ផែនការប្រើប្រាស់ដីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ”

# មាតិកា


| | | |
|---|---|---|
| 01 | អំពី | លក្ខណៈភូមិសាស្ត្រខេត្ត |
| 02 | ការងារ | រៀបចំដែនដី និង នគរូបនីយកម្ម |
| 03 | ផែនការ | ផែនការរៀបចំដែនដីនៅថ្នាក់ខេត្ត |
| 04 | លទ្ធផល | សម្រេចបាននៃការងាររៀចំដែនដី និងនគរូនីយកម្ម |
| 05 | វឌ្ឍនភាព | វឌ្ឍនភាពការងារផែនការប្រើប្រាស់ដីថ្នាក់ឃុំ/សង្កាត់អាទិភាព |
| 06 | អំពី | បញ្ហាប្រឈម និងដំណោះស្រាយ |
| 07 | ទិសដៅ | អនុវត្ត |

# 01 អំពីលក្ខណៈភូមិសាស្ត្រខេត្ត




ខេត្តស្វាយរៀង ស្ថិតនៅទិសអាគ្នេយ៍ ខាងត្បូងឈៀងខាងកើត និងមានចម្ងាយប្រមាណ ១២៥ គ.ម ពីរាជធានីភ្នំពេញ និងមានផ្ទៃដីសរុប ២៩៦៦,៤០ គ.ម២

មានព្រំប្រទល់ខាងលិច និងខាងជើងជាប់នឹងខេត្តព្រៃវែង ខាងកើត និងខាងត្បូងជាប់នឹងខេត្តតៃនីញ (ប្រវែង ២៥៨ គ.ម)
មានក្រុងចំនួន២ និងស្រុកចំនួន៦
មានឃុំ/សង្កាត់សរុបចំនួន៨០ និង ៦៩០ភូមិ ។

មានគ្រួសារសរុបចំនួន ១៦៣,៩៤០គ្រួសារ ស្មើនឹង ៦៨២,៩៤១នាក់ ក្នុងនោះស្ត្រី ៣៥១,៥៦១នាក់ ដង់ស៊ីតេប្រជាជនចំនួន ២៣០នាក់/គ.ម២

មានរោងចក្រសហគ្រាសចំនួន ១.០៨៨កន្លែង មាន កម្មករ កម្មការិនី និងនិយោជិត សរុប ១៥៣.៧៣៣នាក់ និងមានតំបន់សេដ្ឋកិច្ចពិសេសចំនួន ១៣ទីតាំង ។

# 02

# អំពីការងាររៀបចំដែនដី និង នគរូបនីយកម្ម

ផែនការរៀបចំដែនដីថ្នាក់ខេត្ត គឺជាក្របខណ្ឌរៀបចំដែនដី ដើម្បីដោះស្រាយការអភិវឌ្ឍន៍រួម របស់ខេត្ត។ ផែនការនេះពណ៌នា វិភាគអំពីស្ថានភាពបច្ចុប្បន្ននៅក្នុងខេត្ត ពិនិត្យមើលនិន្នាការ និងឱកាសនៃការអភិវឌ្ឍន៍នាពេលអនាគតជាផែនការពហុវិស័យដែលទាក់ទងនឹងទិដ្ឋភាពសំខាន់ៗនៃបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង ជនបទ សកម្មភាពសង្គម និងសេដ្ឋកិច្ចពីទស្សនៈនៃការរៀបចំដែនដី ដើម្បីជាមូលដ្ឋានក្នុងការកសាងទិន្នន័យអំពីការគ្រប់គ្រង ប្រើប្រាស់ដី ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការរៀចំផែនការប្រើប្រាស់ដី និងបែងចែកឱ្យបានត្រឹមត្រូវ ចៀសវាងការប្រើប្រាស់ដីមិនចំសក្តានុពល សំដៅរក្សានូវចីរភាព បរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។



# 03 អំពីផែនការរៀបចំដែនដីនៅថ្នាក់ខេត្ត

## ផែនការរៀបចំដែនដីខេត្ត រួមមានយុទ្ធសាស្ត្រ អនុយុទ្ធសាស្ត្រ និងសកម្មភាពក្រោមគោលដៅរួមចំនួន៩ ៖



**ទី១**

ពង្រឹងមូលដ្ឋានសេដ្ឋកិច្ច និងលើកកំពស់តួនាទីរបស់ខេត្តក្នុងការអភិវឌ្ឍន៍ជាតិ

**ទី២**

ការពារបរិស្ថានធម្មជាតិ និងជីវចម្រុះ

**ទី៣**

បរិស្ថានទីក្រុងមានភាពប្រសើរឡើង

**ទី៤**

លើកកម្ពស់លទ្ធភាពទទួលបានសេវាចំពោះប្រជាពលរដ្ឋគ្រប់រូប

**ទី៥**

កែលម្អគុណភាព និងការគ្របដណ្តប់នៃហេដ្ឋារចនាសម្ព័ន្ធ។ ប្រើប្រាស់គោលនយោបាយអាទិភាពខ្ពស់។ ពិចារណាពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុនៅក្នុងការសម្រេចចិត្តអភិវឌ្ឍន៍គ្រប់យ៉ាង។

# 03 អំពីផែនការរៀបចំដែនដីនៅថ្នាក់ខេត្ត ( ត )

## ដំណើរការទូទៅ នៃការរៀបចំផែនការរៀបចំដែនដី ថ្នាក់ខេត្ត

**01 — រៀបចំការ**
សិក្ខាសាលាផ្សព្វផ្សាយលើសេចក្តីព្រាងការរៀបចំផែនកា)

**02 — ការវិភាគទិន្នន័យ**
សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង និងប្រមូលធាតុចូលនានា

**03 — ចក្ខុវិស័យនិងយុទ្ធសាស្ត្រ**
កិច្ចប្រជុំសម្រេចលើផែនការរៀបចំដែនដី

**04 — ការបញ្ចប់ស្ថាពរ និងអនុម័ត**
កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ដើម្បីអនុម័តលើផែនការរៀបចំដែនដី

**05 — ការគ្រប់គ្រងផែនការ**
ការអនុវត្ត និងតាមដានត្រួតពិនិត្យ

# 04 លទ្ធផល

## ៤.១. ការងារចុះបញ្ជីលើកដំបូង

### ក. ការងារចុះបញ្ជីលើកដំបូងមានលក្ខណៈជាប្រព័ន្ធ

ចាប់ផ្តើមអនុវត្តការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធពីឆ្នាំ២០០៨ មករហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦៖

- ប្រកាសតំបន់វិនិច្ឆ័យបានចំនួន ៦៩០ភូមិ ស្មើនឹង ១០០%
- បិទផ្សាយជាសាធារណៈបានចំនួន ៦៩០ ភូមិ ស្មើនឹង ១០០%
- ក្បាលដីប៉ាន់ស្មានដែលត្រូវចុះបញ្ជីមានចំនួនសរុប ៧៤១,៥៣០ ក្បាលដី
- ក្បាលដីដែលត្រូវបានវាស់វែងមានចំនួនសរុប ៧៤១,៥៣០ ក្បាលដី ស្មើនឹង ១០០%
- បានប្រកាសបិទបញ្ចប់ការវាស់វែងទូទាំងខេត្តនៅ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥

# 04 លទ្ធផល ( ត )

## ៤.១. ការងារចុះបញ្ជីលើកដំបូង

### ក. ការងារចុះបញ្ជីលើកដំបូងមានលក្ខណៈជាប្រព័ន្ធ

ក្បាលដីដែលត្រូវបានការវិនិច្ឆ័យមានចំនួនសរុប ៧៤១,៥៣០ ក្បាលដីស្មើនឹង ១០០%

ក្បាលដីដែលបានចេញបណ្ណមានចំនួនសរុប ៥៨៨,០៣៦ បណ្ណ/ ក្បាលដីស្មើនឹង ៧៩%

បានកំណត់ព្រំប្រទល់ រដ្ឋបាលខេត្តស្វាយរៀង និង រដ្ឋបាលខេត្តព្រៃវែង រួចជាស្ថាពរក្នុងឆ្នាំ២០២៦

ក្បាលដីដែលត្រូវបានធ្វើការបិទផ្សាយមានចំនួនសរុប ៧៤១,៥៣០ ក្បាលដីស្មើនឹង ១០០%

បណ្ណដែលបានចែករួចមានចំនួនសរុប ៥៤៦,០៤៧ បណ្ណ/ ក្បាលដីស្មើនឹង ៧៣%

# 04 លទ្ធផល ( គ )

## ៤.១. ការងារចុះបញ្ជីលើកដំបូង

### ខ.ការចុះបញ្ជីបំពេញបន្ថែម

ក្នុងឆ្នាំ២០២៤ បានចុះបញ្ជីចេញប័ណ្ណកម្មសិទ្ធលក្ខណៈដាច់ដោយដុំ សរុបចំនួន **174** ប័ណ្ណ



# 04 លទ្ធផល ( ត )

## ៤.២. ការចុះបញ្ជីដីរដ្ឋ

### ចុះបញ្ជីដីរដ្ឋ

1. វាស់វែងសរុបចំនួន ៣.២៥១ក្បាលដី
2. ចេញប្លង់បណ្ណរួចចំនួន ២ ៨២៧ ក្បាលដី គិតជាទំហំប្រមាណ ៣ ៤៥៩ ហិកតា

### នីតិវិធីពិសេស

1. ចេញប្លង់បណ្ណចំនួន ៤បណ្ណ ស្មើនឹង ២៨១,៧៣ហិកតា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតនៅភូមិត្រពាំងផ្លុង សង្កាត់បាទី ក្រុងបាវិត
2. កាត់ឆ្វៀលដី ៨៥៥ក្បាលដី ទំហំ ៣៧២,២១ហ.ត ជូនប្រជាពលរដ្ឋ
3. បានស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសលើទីតាំងអាងទឹក និងព្រៃ ចំនួន ១២ទីតាំង ស្មើនឹងទំហំ ៥ ៧៨៨,១៤ ហ.ត

# 04 លទ្ធផល ( គ )

## ផែនការរៀបចំដែនដីខេត្តស្វាយរៀងចក្ខុវិស័យឆ្នាំ២០៤៥៖

- បានរៀបចំក្នុង រយៈពេល ១៩ខែ ចាប់ផ្តើមពីខែមីនា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤។
- តាមរយៈដំណើរការពិគ្រោះយោបល់ ក្នុងនោះបាន រៀបចំធ្វើសិក្ខាសាលាចំនួន៣លើក។
- ការចុះប្រមូលទិន្នន័យ និងប្រជុំនៅគ្រប់ស្រុក/ក្រុងរួម ទាំងកិច្ចប្រជុំប្រមូលធាតុចូល នៅរដ្ឋបាលខេត្តចំនួន មួយលើក ដែលគាំទ្រដោយក្រុមការងារច្នេកទេស ធនាគារអភិវឌ្ឍន៍អាស៊ីហៅកាត់ថា (ADB)។
- បានដាក់សំណើរសុំគោលការណ៍អនុម័តជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនី កម្មនិងសំណង់ និងជាសហប្រធានគណៈកម្មាធិការ រៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិពិនិត្យនិង ឯកភាពនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៤។



# 04 លទ្ធផល ( គ )

- ផែនការតម្រង់ទិសការងាររៀបចំដែនដី និងនគរូបនីយកម្មផ្សារភ្ជាប់របៀងសេដ្ឋកិច្ចខេត្តស្វាយរៀង ចក្ខុវិស័យឆ្នាំ២០៣៥

- មានការគាំទ្រពី ក្រុមការងាររៀបចំផែនការតម្រង់ទិស ការងាររៀបចំដែនដី និងនគរូបនីយកម្មផ្សារភ្ជាប់របៀងសេដ្ឋកិច្ចខេត្តស្វាយរៀងនិងកិច្ចប្រជុំពិនិត្យលើសេចក្តីព្រៀង ក្នុងការផ្សារភ្ជាប់របៀងសេដ្ឋកិច្ច ឆ្នាំ២០២៥ ដល់ឆ្នាំ២០៣៥ បានឯកភាព និងត្រៀមដាក់ស្នើរសុំការអនុម័ត ពីក្រុមប្រឹក្សាខេត្ត។



# 04 លទ្ធផល ( ត )

មានការគាំទ្រពីក្រុមការងាររៀបចំផែនការតម្រង់ទិសការងាររៀបចំដែនដី និងនគរូបនីយកម្ម ផ្សារភ្ជាប់របៀងសេដ្ឋកិច្ចខេត្តស្វាយរៀង ឆ្នាំ២០២៥ដល់ឆ្នាំ២០៣៥របស់ក្រសួងដនសបានធ្វើកិច្ចប្រជុំពិនិត្យលើសេចក្តីព្រៀងក្នុងការផ្សារភ្ជាប់របៀងសេដ្ឋកិច្ចខេត្តស្វាយរៀង ឆ្នាំ២០២៥ ដល់ឆ្នាំ២០៣៥ និងបានអនុវត្តរួចហើយនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ នៅរដ្ឋបាលសាលខេត្តស្វាយរៀង។



# 04 លទ្ធផល ( គ )

## ប្លង់គោលប្រើប្រាស់ដីក្រុងបាវិត

បានបញ្ចប់និងបានអនុម័តដាក់អោយប្រើប្រាស់ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ក្រោយរយៈពេល៥ឆ្នាំនៃការដាក់អោយប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងបាវិត ត្រូវបានក្រុមការងារធនាគារ អភិវឌ្ឍន៍អាស៊ីហៅកាត់ថា (ADB) បានសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដីធ្វើបច្ចុប្បន្នភាព និង បានបញ្ចប់សេចក្តីព្រៀងប្លង់គោលប្រើប្រាស់ដី និង ត្រៀមស្នើរសុំការអនុម័តពីក្រុមប្រឹក្សាខេត្ត។



# 05 វឌ្ឍនភាពការងារផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់អាទិភាព

**STEP 01**
ផែនការប្រើប្រាស់ដី សង្កាត់សង្វ៊ារ ក្រុងស្វាយរៀង ក្នុងឆ្នាំ២០២១

**STEP 02**
ផែនការប្រើប្រាស់ដី ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ក្នុងឆ្នាំ២០២៣

**STEP 03**
ផែនការប្រើប្រាស់ដី ឃុំកណ្ដៀងរាយ ស្រុកស្វាយទាប ក្នុងឆ្នាំ២០២៣

**STEP 04**
ផែនការប្រើប្រាស់ដី ឃុំកំពង់ចក ស្រុករំដួល ក្នុងឆ្នាំ២០២៤

**STEP 05**
ផែនការប្រើប្រាស់ដី ឃុំមេសរថ្ងក ស្រុកចន្ទ្រា ក្នុងឆ្នាំ២០២៥។



# 06 បញ្ហាប្រឈម និងដំណោះស្រាយ



## បញ្ហាប្រឈម

-ប្រជាពលរដ្ឋនៅតែបន្តទន្ទ្រានកាន់កាប់ដីរដ្ឋ អាងទឹក បឹងបួរ ព្រែក និងទន្លេ។

-ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋានអំពីច្បាប់ភូមិបាលនៅមានកម្រិត។

## ដំណោះស្រាយ

-ស្នើសុំក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយអាជ្ញាធរខេត្តក្នុងការកំណត់បោះបង្គោលព្រំដីរដ្ឋ ឱ្យបានច្បាស់លាស់។

-ស្នើសុំឱ្យមានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីអំពីច្បាប់ភូមិបាលដល់អាជ្ញាធរមូលដ្ឋាន។

# 07 ទិសដៅបន្ត

- គណៈកម្មការរៀបចំដែនដីថ្នាក់ខេត្ត នឹងអនុវត្តន៍បន្ត លើការងារ ជ្រើសរើសឃុំ សង្កាត់ អាទិភាព នៅតាមបណ្តាក្រុង ស្រុក លើការងារផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់
- គណៈកម្មការរៀបចំដែនដីថ្នាក់ខេត្ត និងបន្តរៀបចំប្លង់គោលប្រើប្រាស់ដី នៅគ្រប់ក្រុង/ស្រុក ទូទាំងខេត្តដើម្បីជាឧត្តមប្រយោជន៍ដល់ថ្នាក់មូលដ្ឋាន
- ជំរុញការបោះបង្គោលព្រំដីរបស់រដ្ឋឱ្យបានច្បាស់លាស់ ដើម្បីកាត់បន្ថយការរុករានទន្ទ្រានកាន់កាប់ដីរដ្ឋ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជម្រុញការរៀបចំកសាងផែនការប្រើប្រាស់ដីថ្នាក់ឃុំ/សង្កាត់អត្ថិភាពនៅថ្នាក់ក្រោមជាតិ ស្រប តាមគោលការណ៍របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។



# សូមអរគុណ